ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ..៥៣.០៤.សបស/ប្រកបស

# ប្រកាស

## ស្ដីពី

## ការគ្រប់គ្រងអនាម័យ និងសុវត្ថិភាពចំណីអាហារតាមដងផ្លូវ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា

-បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញប្រកាសអន្តរក្រសួងលេខ ៨៦៨ ឧរថ.ប្រកចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ស្ដីពីការអនុវត្តន៍ និងសម្របសម្រួលស្ថាប័នកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារចាប់ពីកសិដ្ឋានផលិតរហូតដល់តុបរិភោគ

-យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល។

ព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល



ទីស្ដីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្ដេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# សម្រេច

**ប្រការ១ .–**

ប្រកាសនេះមានគោលបំណងការពារសុខភាពអ្នកបរិភោគ និងកាត់បន្ថយការពុលចំណីអាហារ ដែលបណ្តាលមកពីចំណីអាហារពុំមានអនាម័យ និងសុវត្ថិភាព។

**ប្រការ២ .–**

ប្រកាសនេះមានគោលដៅគ្រប់គ្រងអនាម័យ និងសុវត្ថិភាពចំណីអាហារ និងផ្តល់លិខិតបញ្ជាក់អនាម័យដល់អ្នកលក់ចំណីអាហារនៅតាមដងផ្លូវ។

**ប្រការ៣ .–**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់អនុវត្តគ្រប់អ្នកលក់ចំណីអាហារនៅតាមដងផ្លូវទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ .–**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងប្រកាសនេះរួមមាន៖

-ចំណីអាហារតាមដងផ្លូវ សំដៅដល់ចំណីអាហារដែលលក់នៅទីតាំងចិញ្ចើមផ្លូវ មុខផ្ទះ ក្នុងផ្ទះ បរិវេណផ្សារ សាលារៀន រមណីយដ្ឋាន មណ្ឌលកំសាន្ត តូប ឬស្តង់លក់អាហារផ្សេងៗទៀតដែលមានទីតាំងកំណត់ច្បាស់លាស់។

**ប្រការ៥ .–**

ភ្នាក់ងារត្រួតពិនិត្យចំណីអាហាររបស់ក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាល រាជធានី ខេត្តមានតួនាទី និងសិទ្ធិអំណាចចុះធ្វើអធិការកិច្ចណែនាំ និងធ្វើការវាយតម្លៃដល់ទីតាំងផ្ទាល់របស់អាជីវករលក់ចំណីអាហារ ដើម្បីធានាអនាម័យ និងសុវត្ថិភាពចំណីអាហារយោងតាមលក្ខខណ្ឌតម្រូវ របស់ក្រសួងសុខាភិបាល និងបទប្បញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធ។

**ប្រការ៦ .–**

ការចុះធ្វើអធិការកិច្ចរួមមាន៖

-ទីតាំងលក់ចំណីអាហារ បរិស្ថាននៅជុំវិញ កន្លែងរៀបចំចំណីអាហារ កន្លែងចំអិនដាំស្ល សម្ភារប្រើប្រាស់សម្រាប់ផលិត និងចំអិនអាហារ

-គ្រឿងផ្សំអាហារ ការសម្អាត ឬសម្លាប់មេរោគ សម្ភារវេចខ្ចប់ កន្លែងទុកដាក់ចំណីអាហារក្នុងសីតុណ្ហភាពសុវត្ថិភាព

-បុគ្គលដែលធ្វើការផ្ទាល់នៅក្នុងទីតាំងលក់ចំណីអាហារ។

**ប្រការ៧ .–**

ភ្នាក់ងារត្រួតពិនិត្យចំណីអាហាររបស់ក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវស្លៀកពាក់ឯកសណ្ឋាននៅពេលចុះទៅបំពេញភារកិច្ចស្ថិតនៅក្រោមបទប្បញ្ញត្តិរបស់ក្រសួងសុខាភិបាលស្របតាមតួនាទី និងភារកិច្ចរបស់ខ្លួន។

**ប្រការ៨ ៈ–**

អ្នកលក់ចំណីអាហារ ត្រូវមានភារកិច្ច ៖

-ការពារពីការចម្លងគ្រោះថ្នាក់នៅគ្រប់ដំណាក់កាលចំអិនអាហារ

-ការរៀបចំ និងទុកដាក់ចំណីអាហារត្រូវទុកដាក់ក្នុងសីតុណ្ហភាពដែលមានសុវត្ថិភាព

-អ្នកប៉ះពាល់ចំណីអាហារ ត្រូវលាងដៃឱ្យបានត្រឹមត្រូវ និងមានអនាម័យខ្លួនប្រាណ ចៀសវាងការចម្លងមេរោគ

-សហការជាមួយភ្នាក់ងារត្រួតពិនិត្យចំណីអាហាររបស់ក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត។

**ប្រការ៩ ៈ–**

មន្ទីរសុខាភិបាលរាជធានី ខេត្តនឹងផ្តល់លិខិតបញ្ជាក់អនាម័យជូនដល់អ្នកលក់ចំណីអាហារតាមដងផ្លូវដូចមានចែងនៅក្នុងប្រការ៨ ក្នុងករណីដែលអ្នកលក់ចំណីអាហារគោរពតាមលក្ខខណ្ឌតម្រូវរបស់ក្រសួងសុខាភិបាល។

**ប្រការ១០ ៈ–**

អ្នកលក់ចំណីអាហារអាចដាក់ពាក្យសុំលិខិតបញ្ជាក់អនាម័យនៅមន្ទីរសុខាភិបាលរាជធានី ខេត្ត ទៅតាមទីតាំងលក់ចំណីអាហារ។

ការបង់ថ្លៃលើការដាក់ពាក្យសុំលិខិតបញ្ជាក់អនាម័យ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងសុខាភិបាលនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១១ ៈ–**

ពាក្យស្នើលិខិតបញ្ជាក់អនាម័យត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

-ពាក្យស្នើសុំ

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចំលងឬលិខិតឆ្លងដែន(ជនបរទេស)

-ប្រវត្តិរូបសង្ខេបរបស់អ្នកលក់ចំណីអាហារដោយមានបិទរូបថត

-លិខិតបញ្ជាក់សុខភាពរបស់បុគ្គលបម្រើចំណីអាហារផ្ទាល់

-រូបថតទីតាំង

-ឯកសារផ្សេងៗ។

**ប្រការ១២ ៈ–**

លិខិតបញ្ជាក់អនាម័យ មានសុពលភាពរយៈពេល០១ឆ្នាំ ហើយត្រូវមានហត្ថលេខា និងត្រារបស់ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត។ មុនផុតកំណត់សុពលភាព ២០ ថ្ងៃ នៃថ្ងៃធ្វើការ អ្នកលក់ចំណីអាហារ ត្រូវដាក់ពាក្យសុំបន្តនៅមន្ទីរសុខាភិបាលរាជធានី ខេត្ត ទៅតាមទីតាំងរបស់ខ្លួន។

**ប្រការ១៣ .–**

បន្ទាប់ពីទទួលបានពាក្យស្នើសុំត្រឹមត្រូវពីអ្នកលក់ចំណីអាហារ ទៅតាមទម្រង់របស់ក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលរាជធានី ខេត្តរួចមក ភ្នាក់ងារត្រួតពិនិត្យចំណីអាហារត្រូវចុះត្រួតពិនិត្យ វាយតម្លៃជូនថ្នាក់ដឹកនាំ ដើម្បីសម្រេចផ្តល់លិខិតបញ្ជាក់អនាម័យជូនដល់អ្នកលក់ចំណីអាហារ នៅក្នុងរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ១៤ .–**

ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្តមានសិទ្ធិផ្តល់ ឬបដិសេធ ដកហូត នូវលិខិតបញ្ជាក់អនាម័យ នៅក្នុងករណីដែលអ្នកលក់ចំណីអាហារពុំបានអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់ក្រសួងសុខាភិបាលឬមន្ទីរសុខាភិបាលរាជធានី ខេត្ត។

**ប្រការ១៥ .–**

បុគ្គលណាដែលក្លែងបន្លំលិខិតបញ្ជាក់អនាម័យ ឬបានប្រព្រឹត្តិបទល្មើសណាមួយ ឬពុំព្រមអនុវត្តតាមខ្លឹមសារដូចមានចែងនៅក្នុងប្រកាសនេះ ត្រូវទទួលការដាក់ពិន័យ និងទោស ស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៦ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧ .–**

នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៩

ម៉ម ប៊ុនហេង

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ (ដើម្បីសហការ)
- សាលារាជធានី ខេត្ត
- ដូចក្នុងប្រការ១៧(ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារនិងកាលប្បវត្តិ